# ធនាគារ អេស៊ីលីដា ភីអិលស៊ី (ធ.អ.ភ)
# កម្រងសំណួរ-ចម្លើយ
# មហាសន្និបាតភាគហ៊ុនិកលើកទី២១ ថ្ងៃទី២២ ខែមេសា ឆ្នាំ២០២១

| ល.រ | សំនួរ | ការឆ្លើយតប |
|---|---|---|
| ១ | តើកិច្ចប្រជុំចាប់ផ្តើមនៅពេលណា? | កិច្ចប្រជុំមហាសន្និបាតភាគហ៊ុនិកនេះចាប់ផ្តើមពីម៉ោង១៤:00 ដល់ ១៦:00 រសៀល នៅថ្ងៃទី២២ ខែមេសា ឆ្នាំ២០២១ (ម៉ោងនៅភ្នំពេញ)។ |
| ២ | តើត្រូវធ្វើដូចម្តេចទើបអាចបោះឆ្នោតតាមប្រព័ន្ធ e-Voting បាន? តើកិច្ចប្រជុំនេះរៀបចំឡើងដោយរបៀបណា? | - ធនាគារនឹងផ្ញើ QR Code សម្រាប់ការបោះឆ្នោត ជូនភាគហ៊ុនិកម្នាក់ៗ តាមរយៈ**អ៊ីម៉ែល** ក្នុងអំឡុងថ្ងៃទី១៩ ខែមេសា ឆ្នាំ២០២១ ចាប់ពីម៉ោង ៧:៣០ ព្រឹក រហូតដល់ថ្ងៃទី២២ ខែមេសា ឆ្នាំ២០២១ វេលាម៉ោង ១៤:00 រសៀល (ម៉ោងនៅភ្នំពេញ)។<br>- ដូច្នេះភាគហ៊ុនិកម្នាក់ៗត្រូវរក្សា QR Code នេះទុកសម្រាប់ការបោះឆ្នោត ដែលនឹងប្រារព្ធនៅថ្ងៃទី២២ ខែមេសា ឆ្នាំ២០២១ ចាប់ពីម៉ោង ១៤:00 រហូតដល់ម៉ោង ១៦:00 រសៀល (ម៉ោងនៅភ្នំពេញ)។<br>**បញ្ជាក់**:<br>រាល់ចម្ងល់បន្ថែមពាក់ព័ន្ធនឹងការបោះឆ្នោតតាមប្រព័ន្ធ e-Voting សូមពិនិត្យមើល **"សេចក្តីណែនាំអំពីការបោះឆ្នោតប្រព័ន្ធ e-Voting"** ដូចបានភ្ជាប់ជូនមកជាមួយ។ |
| ៣ | តើកិច្ចប្រជុំនេះរៀបចំឡើងដើម្បីអ្វី? | កិច្ចប្រជុំនេះរៀបចំឡើងដើម្បីស្នើសុំម្ចាស់ភាគហ៊ុនិកសម្រេចតាមរបៀបវារៈនីមួយៗ ដែលរៀបចំឡើងដោយក្រុមប្រឹក្សាភិបាល តាមរយៈការបោះឆ្នោត។ |
| ៤ | តើការបោះឆ្នោតភាគហ៊ុនិកនឹងត្រូវរៀបចំឡើងយ៉ាងដូចម្តេចខ្លះ? | សូមមើលលម្អិតនៅក្នុងចម្លើយនៃ**សំនួរទី២**ខាងលើ។ |
| ៥ | ហេតុអ្វីបានជាខ្ញុំមិនទទួលបានលិខិតអញ្ជើញចូលរួមកិច្ចប្រជុំ? | ដោយសារភាគហ៊ុនិកមិនមានឈ្មោះនៅក្នុងបញ្ជីឈ្មោះភាគហ៊ុនិក នៅកាលបរិច្ឆេទកំណត់ទុក សម្រាប់ចូលរួមកិច្ចប្រជុំភាគហ៊ុនិក។ |

ចុះបញ្ជីក្រោមលេខ
Registration No. 00003077
អគារលេខ៦១ មហាវិថីព្រះមុនីវង្ស សង្កាត់ស្រះចក ខណ្ឌដូនពេញ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
#61, Preah Monivong Blvd., Sangkat Srah Chork, Khan Daun Penh, Phnom Penh, Kingdom of Cambodia.
ទូរស័ព្ទ Tel: +855 (0) 23 998 777 / 430 999, ទូរសារ Fax: +855 (0) 23 430 555, ប្រអប់សំបុត្រ P.O.Box: 1149
E-mail: acledabank@acledabank.com.kh, Website: www.acledabank.com.kh, SWIFT Code: ACLBKHPP

| ល.រ | សំនួរ | ការឆ្លើយតប |
|---|---|---|
| ៦ | តើអ្វីទៅជា កាលបរិច្ឆេទកំណត់ទុក សម្រាប់**ចូលរួមកិច្ចប្រជុំភាគហ៊ុនិក**? | កាលបរិច្ឆេទកំណត់ទុក សម្រាប់ចូលរួមកិច្ចប្រជុំភាគហ៊ុនិក គឺជាកាលបរិច្ឆេទប្រកាសបញ្ជីឈ្មោះភាគហ៊ុនិកដែលត្រូវចូលរួម ឬមានសិទ្ធិចូលរួមក្នុងកិច្ចប្រជុំភាគហ៊ុនិក។<br>ឧទាហរណ៍: **៣១ មីនា ២០២១** គឺជាកាលបរិច្ឆេទកំណត់ទុក សម្រាប់ចូលរួមកិច្ចប្រជុំភាគហ៊ុនិក<br>លោក “ក” ទិញភាគហ៊ុនរបស់ ABC នៅថ្ងៃទី២៩ មីនា ២០២១។<br>លោក “ខ” ទិញភាគហ៊ុនរបស់ ABC នៅថ្ងៃទី៣០ មីនា ២០២១។<br>លោក “គ” អត់បានទិញភាគហ៊ុនរបស់ ABC នៅថ្ងៃទី២៩ មីនា ២០២១ទេ ប៉ុន្តែលោក “គ” នៅមានសមតុល្យ ១ភាគហ៊ុនគិតត្រឹមថ្ងៃទី២៩ មីនា ២០២១ (លោក “គ” បានទុក ១ ភាគហ៊ុននេះ ដោយមិនបានលក់ភាគហ៊ុននេះចេញទេនៅថ្ងៃទី២៩ មីនា ២០២១)។<br>ដូច្នេះ**លោក “ក”** និង **លោក “គ” ទទួលបាន**លិខិតអញ្ជើញចូលរួមប្រជុំភាគហ៊ុនិក រីឯ **លោក “ខ” មិនទទួលបាន**លិខិតអញ្ជើញចូលរួមប្រជុំភាគហ៊ុនិកទេ។<br>**បញ្ជាក់**:<br>ដើម្បីទទួលបានលិខិតអញ្ជើញ**ចូលរួមកិច្ចប្រជុំភាគហ៊ុនិក** ភាគហ៊ុនិកត្រូវទិញភាគហ៊ុន (យ៉ាងតិចណាស់ ១ភាគហ៊ុន) ឱ្យបានយ៉ាងហោចណាស់ត្រឹម ២ ថ្ងៃ នៃថ្ងៃជួញដូរ មុនថ្ងៃប្រកាសបញ្ជីឈ្មោះភាគហ៊ុនិកដែលត្រូវចូលរួម ឬមានសិទ្ធិ**ចូលរួមកិច្ចប្រជុំភាគហ៊ុនិក**។ |
| ៧ | តើ កាលបរិច្ឆេទកំណត់ទុក មានប៉ុន្មានប្រភេទ? | កាលបរិច្ឆេទកំណត់ទុក មានពីរប្រភេទគឺ:<br>1. កាលបរិច្ឆេទកំណត់ទុក សម្រាប់ចូលរួមកិច្ចប្រជុំភាគហ៊ុនិក<br>2. កាលបរិច្ឆេទកំណត់ទុក សម្រាប់ទទួលបានភាគលាភ |
| ៨ | តើអ្វីទៅជា កាលបរិច្ឆេទកំណត់ទុក សម្រាប់ទទួលបាន**ភាគលាភ**? | កាលបរិច្ឆេទកំណត់ទុក សម្រាប់ទទួលបានភាគលាភ គឺជាកាលបរិច្ឆេទប្រកាសបញ្ជីឈ្មោះភាគហ៊ុនិកដែលត្រូវទទួល ឬមានសិទ្ធិទទួលបានភាគលាភ។<br>ឧទាហរណ៍: **០៣ ឧសភា ២០២១** គឺជាកាលបរិច្ឆេទកំណត់ទុក សម្រាប់ទទួលបានភាគលាភ<br>*(ថ្ងៃទី៣០ មេសា ២០២១, ០១ ឧសភា ២០២១ និង០២ ឧសភា ២០២១: ជាថ្ងៃឈប់សម្រាក)*<br>លោក “ក” ទិញភាគហ៊ុនរបស់ ABC នៅថ្ងៃទី២៨ មេសា ២០២១។<br>លោក “ខ” ទិញភាគហ៊ុនរបស់ ABC នៅថ្ងៃទី៣០ មេសា ២០២១។<br>លោក “គ” អត់បានទិញភាគហ៊ុនរបស់ ABC នៅថ្ងៃទី២៨ មេសា ២០២១ទេ ប៉ុន្តែលោក “គ” នៅមានសមតុល្យ ១ភាគហ៊ុនគិតត្រឹមថ្ងៃទី២៨ មេសា ២០២១ (លោក “គ” បានទុក ១ភាគហ៊ុននេះ ដោយមិនបានលក់ភាគហ៊ុននេះចេញទេនៅថ្ងៃទី២៨ មេសា ២០២១)។<br>ដូច្នេះ**លោក “ក”** និង **លោក “គ”** ទទួលបានភាគលាភ រីឯ**លោក “ខ”**មិនទទួលបានភាគលាភទេ។<br>**បញ្ជាក់**:<br>ដើម្បីទទួលបាន**ភាគលាភ** ភាគហ៊ុនិកត្រូវទិញភាគហ៊ុន (យ៉ាងតិចណាស់ ១ភាគហ៊ុន) ឱ្យបានយ៉ាងហោចណាស់ត្រឹម ២ នៃថ្ងៃជួញដូរ ថ្ងៃមុនថ្ងៃប្រកាសបញ្ជីឈ្មោះភាគហ៊ុនិកដែលត្រូវទទួល ឬមានសិទ្ធិទទួលបាន**ភាគលាភ**។ |
| ៩ | ប្រសិនបើភាគហ៊ុនិកណាម្នាក់ពុំបានចូល Scan QR Code តាមម៉ោងកំណត់ តើនឹងចាត់ទុកថាគេ បានចូលរួមការប្រជុំដែរឬទេ? | ប្រសិនបើភាគហ៊ុនិកណាម្នាក់ពុំបានចូល Scan QR Code តាមម៉ោងកំណត់ នឹងចាត់ទុកថា “គេមិនបានចូលរួមការប្រជុំ ឬគេបោះបង់សិទ្ធិក្នុងការចូលរួមការប្រជុំ”។ |

| ល.រ | សំនួរ | ការឆ្លើយតប |
|---|---|---|
| ១០ | ប្រសិនបើភាគហ៊ុនិកណាម្នាក់បានចូល Scan QR Code តាមម៉ោងកំណត់ ប៉ុន្តែ**មិនបានបោះឆ្នោតតាមរបៀបវារៈទាំងអស់** តើនឹងចាត់ទុកថា គេបានចូលរួមកិច្ចប្រជុំដែរឬទេ? | ប្រសិនបើភាគហ៊ុនិកណាម្នាក់បានចូល Scan QR Code តាមម៉ោងកំណត់ ប៉ុន្តែមិនបានបោះឆ្នោតតាម**របៀបវារៈទាំងអស់** ភាគហ៊ុនិកនោះនឹងត្រូវចាត់ទុកថាមិនបានចូលរួមកិច្ចប្រជុំ។ |
| ១១ | ប្រសិនបើភាគហ៊ុនណាម្នាក់បានចូល Scan QR Code តាមម៉ោងកំណត់ ប៉ុន្តែ**មិនបានបោះឆ្នោតរបៀបវារៈណាមួយ** តើនឹងចាត់ទុកថា គេបានចូលរួមកិច្ចប្រជុំដែរឬទេ? ហើយរបៀបវារៈនោះនឹងចាត់ទុកដូចម្តេច? | ប្រសិនបើភាគហ៊ុនិកណាម្នាក់បានចូល Scan QR Code តាមម៉ោងកំណត់ ប៉ុន្តែបោះឆ្នោតបានតែរបៀបវារៈមួយចំនួន ភាគហ៊ុនិកនោះនឹងត្រូវចាត់ទុកថាបានចូលរួមកិច្ចប្រជុំ ប៉ុន្តែ**របៀបវារៈនៅសល់**ដែលមិនបានបោះឆ្នោតទាំងនោះត្រូវចាត់ទុកថាជា "**សម្លេងឆ្នោតអនុបវាទ**"។ |
| ១២ | តើភាគលាភសម្រាប់ឆ្នាំ២០២០ដែលនឹងបែងចែកមានប្រភេទអ្វីខ្លះ? | ភាគលាភសម្រាប់ឆ្នាំ២០២០ នឹងបែងចែក**ជាសាច់ប្រាក់**។ |
| ១៣ | តើភាគហ៊ុនិកម្នាក់ៗនឹងទទួលបានភាគលាភនៅពេលណា? | ភាគហ៊ុនិកម្នាក់ៗនឹងទទួលបានភាគលាភនៅក្នុងអំឡុងពេល**៧ថ្ងៃ** នៃថ្ងៃធ្វើការ បន្ទាប់ពី Record date សម្រាប់ទទួលបានភាគលាភ។ ថេរវេលានេះ នឹងមានការផ្លាស់ប្តូរ អាស្រ័យលើការអនុម័តពីនិយ័តករ។ |
| ១៤ | តើធនាគារបានកំណត់អត្រាភាគលាភដែលនឹងត្រូវចែកប្រចាំឆ្នាំនីមួយៗយ៉ាងដូចម្តេច? | ប្រែប្រួលតាមប្រាក់ចំណេញនៃឆ្នាំនីមួយៗ តាមការ**សម្រេចរបស់ភាគហ៊ុនិក និងគោលការណ៍ភាគលាភរបស់ធនាគារ**។ |
| ១៥ | នៅមុនពេលប្រជុំ តើភាគហ៊ុនិកម្នាក់ៗត្រូវធ្វើអ្វីខ្លះ? | សូមមើលលម្អិតនៅក្នុងចម្លើយនៃ**សំនួរទី២**ខាងលើ។ |
| ១៦ | តើភាគហ៊ុនិកម្នាក់ៗ ត្រូវត្រៀមឧបករណ៍អ្វីខ្លះ សម្រាប់កិច្ចប្រជុំនេះ? | ភាគហ៊ុនិកម្នាក់ៗ ត្រូវត្រៀមកុំព្យូទ័រ ទូរស័ព្ទដៃ ឬ Tablet និងប្រព័ន្ធអ៊ីនធឺណិត ដើម្បីធានាថា អាចចូលរួមកិច្ចប្រជុំ និងបោះឆ្នោតបានដោយរលូន។ |
| ១៧ | នៅក្នុងអំឡុងពេលបោះឆ្នោត តើភាគហ៊ុនិកម្នាក់ៗ ត្រូវធ្វើអ្វីខ្លះ? | ក្នុងអំឡុងពេលបោះឆ្នោត ភាគហ៊ុនិកម្នាក់ៗ ត្រូវបើកកុំព្យូទ័រ ទូរស័ព្ទដៃ ឬ Tablet និងភ្ជាប់អ៊ីនធឺណិត រួចឆែកមើលអ៊ីម៉ែល និងបើក QR Code ដែលបានភ្ជាប់ជូនមកជាមួយ រួចហើយបើកកាមេរ៉ាទូរស័ព្ទដៃ និង Scan QR Code នោះ ដើម្បីធ្វើការបោះឆ្នោតតាមរបៀបវារៈនីមួយៗ ស្របតាមឆន្ទៈរបស់ខ្លួន។ |
| ១៨ | ប្រសិនបើភាគហ៊ុនិកណាម្នាក់ខកខានពុំបានចូលរួមកិច្ចប្រជុំនេះ ឬការបោះឆ្នោតតាមរបៀបវារៈនីមួយៗ តើគាត់នឹងបាត់បង់អត្ថប្រយោជន៍ដែរទេ? បើបាត់បង់មានអ្វីខ្លះ? | ភាគហ៊ុនិកណាម្នាក់ ដែលខកខានពុំបានចូលរួមកិច្ចប្រជុំនេះគឺពុំបាត់បង់អត្ថប្រយោជន៍អ្វីនោះទេ ក្រៅពីសិទ្ធិក្នុងការសម្រេចតាមរបៀបវារៈនីមួយៗ។ |

| ល.រ | សំនួរ | ការឆ្លើយតប |
|---|---|---|
| ១៩ | តើភាគហ៊ុនិកម្នាក់ៗ អាចធ្វើការបោះឆ្នោតមុន ឬក្រោយពេលវេលាកំណត់បានដែរឬទេ? | ភាគហ៊ុនិកម្នាក់ៗ ពុំអាចធ្វើការបោះឆ្នោតនៅមុនពេល ឬក្រោយពេលវេលាកំណត់បាននោះទេ។ ពេលវេលាបោះឆ្នោតគឺនៅថ្ងៃទី២២ ខែមេសា ឆ្នាំ២០២១ ចាប់ពីម៉ោង ១៤៖០០នាទី ដល់ម៉ោង ១៦៖០០នាទី (ម៉ោងនៅភ្នំពេញ)។ |
| ២០ | នៅក្រោយពេលកិច្ចប្រជុំចប់ តើភាគហ៊ុនិកម្នាក់ៗ នឹងទទួលបានអ្វីខ្លះ? | នៅក្រោយកិច្ចប្រជុំចប់ ភាគហ៊ុនិកម្នាក់ៗនឹងទទួលបានព័ត៌មាន ស្តីពីលទ្ធផលនៃបោះឆ្នោតតាមរបៀបវារៈនីមួយៗ ។ |

# សេចក្តីណែនាំអំពីការបោះឆ្នោត ប្រព័ន្ធ e-Voting

## 1- លក្ខខណ្ឌតម្រូវសម្រាប់ការបោះឆ្នោត

- លោក លោកស្រី អ្នកនាង កញ្ញា នឹងទទួលបាន QR កូដ សម្រាប់បោះឆ្នោត តាមរយៈអ៊ីម៉ែលផ្ទាល់ខ្លួន
- ការបោះឆ្នោតតាមរបៀបវារៈនីមួយៗ នឹងធ្វើឡើងតាមរយៈទូរស័ព្ទចល័ត ឬ Tablet
- ដើម្បីបោះឆ្នោតបាន ទូរស័ព្ទចល័ត ឬ Tablet របស់លោក លោកស្រី អ្នកនាង កញ្ញា ត្រូវមានភ្ជាប់ប្រព័ន្ធអ៊ីនធើណែត (Internet) ឬ Wifi

### សម្រាប់ប្រព័ន្ធ **IOS**

សូមអនុវត្តការណែនាំខាងក្រោម ករណី Camera មិនអាចដំណើរការស្កេន QR កូដ បាន៖




### សម្រាប់ប្រព័ន្ធ **ANDROID**

លោកគ្រូអ្នកគ្រូត្រូវទាញយកកម្មវិធី/ QR & Barcode Scanner នៅលើ ទូរស័ព្ទ តាមរយៈ Google Play Store ដោយអនុវត្តដូចខាងក្រោម៖



## 2- ការបោះឆ្នោត

<u>សម្រាប់ប្រព័ន្ធ **IOS**</u>

- បើក Camera នៅលើទូរស័ព្ទ ឬ Tablet ដើម្បីស្កេន QR Code ដែលទទួលបានតាមរយៈអ៊ីម៉ែល
- លោក លោកស្រី អ្នកនាង កញ្ញា នឹងអាចចូលទៅកាន់គេហទំព័របោះឆ្នោត




<u>សម្រាប់ប្រព័ន្ធ **ANDROID**</u>

- បើកកម្មវិធី **QR & Barcode Scanner** ដែលបានទាញយករួច ដើម្បីស្កេន QR Code ដែលទទួលបានតាមរយៈអ៊ីម៉ែល
- លោក លោកស្រី អ្នកនាង កញ្ញា នឹងអាចចូលទៅកាន់គេហទំព័របោះឆ្នោត









- ក្រោយការបោះឆ្នោតបានបញ្ចប់ សូមចុចប៊ូតុង " បន្ទាប់" ដើម្បីបោះឆ្នោតលើរបៀបវារៈបន្តបន្ទាប់ទៀតរហូតដល់បញ្ចប់។


8:30
ID 123456
FIRST ANNUAL GENERAL MEETING OF SHAREHOLDERS
| Second Agenda
See More
| VOTE FOR
| VOTE AGAINST
| ABSTAIN


FIRST ANNUAL GENERAL MEETING OF SHAREHOLDERS
| First Agenda
You have selected "VOTE FOR".
Are you sure?
CANCEL
OK
| VOTE AGAINST
| ABSTAIN


8:30
Voting completed
Thank you very much

ೋೋೋ❈ಌಌಌ